ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តក្រចេះ
គណៈកម្មាធិការខេត្តជំរុញចលនាភ១ផ១
លេខ០០១/២០...រ.ប.ក

# របាយការណ៍
# ស្តីពី
# សកម្មភាពការងារប្រចាំ ឆមាសទី១ ឆ្នាំ២០២០

## ១. ស្ថានភាពទូទៅ៖

ខេត្តក្រចេះ ជាខេត្តគោលដៅមួយ ក្នុងចំណោមខេត្តទាំងប្រាំពីរ នៃការអនុវត្តចលនាភូមិមួយ ផលិតផលមួយ ដែលមានព្រំប្រទល់ខាងលិចទល់នឹងខេត្តកំពង់ធំ ខាងកើតទល់នឹងខេត្តមណ្ឌលគិរី និងប្រទេសវៀតណាម ខាងជើងទល់នឹងខេត្តស្ទឹងត្រែង និងខាងត្បូងទល់នឹងខេត្តត្បូងឃ្មុំ និងកំពង់ចាម ។ ខេត្តក្រចេះមានផ្ទៃ ដីសរុបចំនួន ១១.០៩៤ គីឡូម៉ែត្រការ៉េ មានក្រុង១ ស្រុក៥ ក្នុងនោះមាន៤២ឃុំ ៥សង្កាត់ និងមាន២៥៨ភូមិ មានប្រជាជនចំនួន ៤១៧.៣២១ នាក់ ក្នុងនោះស្រីចំនួន២១០.៨៣៧នាក់ ស្មើនឹង៩៤.០៨០គ្រួសារ ដែលមានដង់ស៊ីតេប្រជាជន ៣៧នាក់ក្នុង១គីឡូម៉ែត្រការ៉េ ។

## ២. សក្តានុពលរបស់ខេត្ត៖

ខេត្តក្រចេះស្ថិតនៅភូមិភាគឦសាន្តនៃប្រទេសកម្ពុជា ដែលមានស្ថានភាពដីជាពីរប្រភេទធំៗគឺតំបន់ខ្ពង់រាប និងតំបន់ទំនាប ដែលសំបូរដោយធនធានធម្មជាតិ ប្រជាពលរដ្ឋនៅខេត្តក្រចេះមាន៨១.៥%គ្រួសារជាកសិករពឹងផ្អែកទាំងស្រុងលើវិស័យកសិកម្ម ដែលជាវិស័យចម្បងក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួន ។ ដើម្បីលើកកំពស់ជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ គណៈកម្មាធិការភូមិមួយផលិតផលមួយខេត្តកំពុងសិក្សាកំណត់យកនូវផលិតផល សក្តានុពលមួយចំនួន ដើម្បីជំរុញផលិតផលទាំងនោះឲ្យក្លាយជា ភ១ផ១ របស់ខេត្តមានដូចជា៖ នំក្រឡាន ផ្លែក្រូចថ្លុង រូបចម្លាក់វត្ថុអនុស្សាវរីយ៍ ផលិតផលកែច្នៃពីដើមឫស្សី ផលិតផលកែច្នៃពីធាងដើមទ្រាំង តំបន់ទេសចរណ៍ធម្មជាតិជាដើម ។

## ៣. លទ្ធផលសម្រេចបានប្រចាំឆមាសទី០១ ឆ្នាំ២០២០៖

| ល.រ | សកម្មភាពអាទិភាព | សម្រេចបាន % | ខែ | | | | | |
|---|---|---|---|---|---|---|---|---|
| | | | ០១ | ០២ | ០៣ | ០៤ | ០៥ | ០៦ |
| ១ | ប្រជុំគណៈកម្មាធិការខេត្ត ភ១ផ១ ស្តីពីការជំរុញស្រាវជ្រាវ ផលិតផលសក្តានុពល | ០២លើក | | ✓ | | | | ✓ |

Scanned with CamScanner

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២ | ប្រជុំក្រុមលេខាធិការពិនិត្យរៀបចំផែនការសកម្មភាពការងារ ភ១ផ១ខេត្ត | ០១លើក | | | ✓ | | | |
| ៣ | ប្រជុំក្រុមលេខាធិការ ភ១ផ១ ខេត្ត ជាមួយ ភ១ផ១ ថ្នាក់ជាតិ ជំរុញការធ្វើផែនការសកម្មភាព | ០១លើក | | | ✓ | | | |
| ៤ | ប្រជុំគណៈកម្មាធិការខេត្ត ភ១ផ១ស្តីពីការពិនិត្យ ឯកភាពលើផែនការសកម្មភាព ភ១ផ១ខេត្ត ឆ្នាំ២០១៨ | ០១លើក | | | ✓ | | | |
| ៥ | នាំយកផលិតផលសក្តានុ ពលខេត្ត ទៅតាំងបង្ហាញតាមបណ្តារាជធានី,ខេត្ត,និងក្រៅប្រទេស | ០១លើក | | | ✓ | | | |
| ៦ | រៀបចំការតាំងបង្ហាញផលិផលសក្តានុពលក្នុងខេត្ត (ទិវាសត្វផ្សោតទន្លេមេគង្គ) | ០១លើក | | | | | | |
| ៧ | ចូលរួមប្រជុំ,សិក្ខាសាលាថ្នាក់ជាតិស្តីពី គោលនយោបាយ ភ១ផ១ | ០១លើក | | | ✓ | | | |
| ៨ | ប្រជុំប្រចាំត្រីមាសនីមួយៗ | ០៤លើក | | | ✓ | | | ✓ |
| ៩ | ផ្សព្វផ្សាយ និងធ្វើបទសំភាសន៍ជាមួយវិទ្យុខេត្ត | ០១លើក | | | | | | |
| ១០ | ផ្សព្វផ្សាយតាមបណ្តាញ ព័ត៌មានសង្គម (Facebook) | មិនកំណត់ | | | ✓ | ✓ | ✓ | ✓ |

## ៤. ផលិតផលសក្តានុពលក្នុងខេត្តរួមមាន៖

| ល.រ | ឈ្មោះផលិតផល | ទីតាំងផលិត |
|---|---|---|
| ១ | នំក្រឡាន | ឃុំថ្មគ្រែ ស្រុកចិត្របុរី |
| ២ | ណែមសាច់ត្រី | សង្កាត់រការកណ្តាល សង្កាត់ក្រគរ ក្រុងក្រចេះ |
| ៣ | ក្រូចថ្លុងកោះទ្រង់ | សង្កាត់កោះទ្រង់ ក្រុងក្រចេះ |
| ៤ | ស្រូវនាងអំ | ឃុំសណ្តាន់ ស្រុកសំបូរ ឃុំស្វាយជ្រះ ស្រុកស្នួល |
| ៥ | ស្រូវផ្ការំដួល | ឃុំសណ្តាន់ ស្រុកសំបូរ |
| ៦ | ស្រូវផ្ការខ្ញុំ | ឃុំអូរគ្រៀង ស្រុកសំបូរ |
| ៧ | ចេកអំបូងលឿង | ឃុំឃ្សឹម និង ឃុំត្រពាំងសែនជ័យ ស្រុកស្នួល |
| ៨ | ពោតក្រហម | ឃុំកោះច្រែង ឃុំកោះតាស៊ុយ ស្រុកចិត្របុរី |
| ៩ | ឥដ្ឋ ក្បឿង | ឃុំបុសលាវ ឃុំថ្មគ្រែ ស្រុកចិត្របុរី |
| ១០ | ចម្លាក់អនុស្សាវរីយ៍អំពីឈើ | ឃុំសំបុក ស្រុកចិត្របុរី |
| ១១ | តម្បាញក្រម៉ា | នៅមជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី |
| ១២ | ទឹកស៊ីអ៊ីវ | ធ្វើជាលក្ខណៈគ្រួសារនៅក្រុងក្រចេះ |

Scanned with CamScanner

## ៥. បញ្ហាប្រឈមៈ

| ល.រ | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| ១ | ខ្វះមធ្យោបាយចុះមូលដ្ឋាន | ពុំទាន់មាន |
| ២ | ខ្វះសម្ភារៈរដ្ឋបាល ( កុំព្យូទ័រ ព្រីនធ័រ ម៉ាស៊ីនCopy ក្រដាស..) | ពុំទាន់មាន |
| ៣ | ក្រុមលេខាធិការពុំទាន់មានបទពិសោធន៍ពេញលេញ កំពង់ស្វែងយល់ផង និងអនុវត្តន៍ផងក្នុងការអនុវត្តការងារជំរុញចលនា ភ១ផ១ | បន្តខិតខំ |
| ៤ | បច្ចេកទេសផលិតនៅមានកំរិត | ស្វែងរកទុនពីដៃគូអាជីវកម្ម និងធនាគារ |
| ៥ | ខ្វះទីផ្សារលក់ចេញ | |
| ៦ | ខ្វះបច្ចេកទេសវេចខ្ចប់ និងរក្សាគុណភាព | បើកវគ្គបណ្តុះបណ្តាលជូនសិប្បករ |
| ៧ | លេខាធិការដ្ឋានអាក់ខានដំណើការមួយរយៈដោយសារជំងឺកូវីត១៩ | |

## ៦. ទិសដៅអនុវត្តបន្តៈ

### ៦.១.សកម្មភាពអាទិភាព

- បន្តរៀបចំរបាយការណ៍ប្រចាំត្រីមាស/ឆមាស
- បន្តប្រជុំប្រចាំត្រីមាសជាប្រចាំ
- បន្តប្រជុំជាមួយអនុគណៈកម្មការថ្នាក់ក្រុង/ស្រុក ដើម្បីពង្រឹងការងារអោយកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត
- បន្តផ្សព្វផ្សាយកម្រងសំនួរប្រមូលព័ត៌មាន ទិន្នន័យ គ្រប់ស្ថាប័នពាក់ពន្ធ័
- បន្តការប្រមូលទិន្នន័យពាក់ព័ន្ធពីបណ្តាលមន្ទីរ/ស្ថាប័ន
- បន្តដំណើរការរៀបចំរបាយការណ៍ពិនិត្យនិងបញ្ចូលទិន្នន័យ
- បន្តប្រជុំពិនិត្យ និងបូកសរុបទិន្នន័យផលិតផលសក្តានុពលក្នុងខេត្ត
- បន្តជម្រុញការសុំចូលជាសមាជិក ភ១ផ១
- បន្តនាំយកផលិតផលសក្តានុពល ចូលរួមពិព័រណ៌ក្នុង និងក្រៅប្រទេស
- បន្តផ្សព្វផ្សាយគោលនយោបាយថ្នាក់ជាតិស្តីពី ភ១ផ១ អោយបានទូលំទូលាយបន្តទៀត
- បន្តផ្សព្វផ្សាយ និងធ្វើបទសំភាសន៍ជាមួយវិទ្យុខេត្ត
- បន្តផ្សព្វផ្សាយតាមបណ្តាញព័ត៌មានសង្គម (Facebook)

ថ្ងៃព្រហស្បតិ៍ ១០រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ក្រចេះ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០២០
**អ្នកធ្វើរបាយការណ៍**

**សំអាត_មានិត**

**បានឃើញ និ ឯកភាព**
ថ្ងៃសុក្រ ១០រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ក្រចេះ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០២០
**អភិបាលខេត្ត និងជា**
**ប្រធានគណៈកម្មាធិការខេត្តជំរុញចលនា ភ១ផ១**

**វ៉ា ថន**

Scanned with CamScanner